**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ១០១...អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពីការបង្កើតគណៈកម្មាធិការ
## កំណត់ផ្ទៃទីតាំងបឹងបួរ ក្នុងព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១** : ត្រូវបានបង្កើតគណៈកម្មាធិការកំណត់ផ្ទៃទីតាំងបឹងបួរ ក្នុងព្រះរាជាណាចក្រកម្ពុជា រួមមានសមាសភាព ដូចខាងក្រោម :

១- ឯកឧត្តម **លឹម គានហោ** រដ្ឋមន្ត្រី ក្រសួងធនធានទឹក និងឧតុនិយម ប្រធាន

២- ឯកឧត្តម **អ៊ឹម ឈុនលឹម** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អនុប្រធាន

៣- ឯកឧត្តម **ច័ន្ទ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

៤- ឯកឧត្តម **ម៉ុង ម៉ារ៉េន** អគ្គនាយកកិច្ចការបច្ចេកទេសក្រសួងធនធានទឹក និងឧតុនិយម សមាជិក

៥- ឯកឧត្តម **ឆៅ ធួក** ប្រធានរដ្ឋបាលជលផលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

៦- អភិបាលខេត្ត-ក្រុង សមាជិក ។

**មាត្រា ២ :** គណៈកម្មាធិការកំណត់ផ្ទៃទីតាំងបឹងបូរ ក្នុងព្រះរាជាណាចក្រកម្ពុជា មានភារកិច្ចដូចតទៅ :

- ជាសេនាធិការផ្ទាល់របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ដើម្បីត្រួតពិនិត្យ និងតាមដានលើសកម្មភាពប្រើប្រាស់បឹងបូរ ក្នុងព្រះរាជាណាចក្រកម្ពុជា
- ចុះសិក្សា និងកំណត់ផ្ទៃទីតាំងបឹងបូរ ដើម្បីលើកយោបល់ ជូនសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ពិនិត្យសម្រេច
- ពិនិត្យ និងលើកយោបល់សុំការសម្រេចពី ប្រមុខរាជរដ្ឋាភិបាល ដើម្បីលុបចោលនូវរាល់ឯកសារទាំងឡាយណា ដែលទាក់ទងនឹងករណីទន្ទ្រានកាន់កាប់បឹងបូរ ក្នុងក្របខ័ណ្ឌទូទាំងប្រទេស
- ធ្វើរបាយការណ៍ពីលទ្ធផលការងារ ដែលអនុវត្តបាន ជូនប្រមុខរាជរដ្ឋាភិបាល ។

**មាត្រា ៣ :** គណៈកម្មាធិការកំណត់ផ្ទៃទីតាំងបឹងបូរ ក្នុងព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងធនធានទឹក និងឧតុនិយម លើរាល់លិខិតស្នាម និងមានថវិកាដោយឡែករបស់ខ្លួន ដែលភ្ជាប់ទៅនឹងគណនីយរបស់ក្រសួងធនធានទឹក និងឧតុនិយម ។

គណៈកម្មាធិការកំណត់ផ្ទៃទីតាំងបឹងបូរ ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន ។

**មាត្រា ៤ :** គណៈកម្មាធិការកំណត់ផ្ទៃទីតាំងបឹងបូរ ក្នុងព្រះរាជាណាចក្រកម្ពុជា មានលេខាធិការដ្ឋានមួយ ជាជំនួយការការងារ នៅទីស្តីការក្រសួងធនធានទឹក និងឧតុនិយម ។ លេខាធិការដ្ឋាននេះ ត្រូវដឹកនាំដោយប្រធានមួយរូប និងជំនួយការ មួយចំនួនតាមការចាំបាច់ ។ មន្ត្រីជំនួយការក្នុងលេខាធិការដ្ឋាននេះ ជាមន្ត្រីរបស់ក្រសួងធនធានទឹក និងឧតុនិយម ឬ ជាមន្ត្រី ក្របខ័ណ្ឌមកពីក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល ដែលទទួលការតែងតាំងពីប្រធានគណៈកម្មាធិការ ។

**មាត្រា ៥ :** លេខាធិការដ្ឋាន នៃគណៈកម្មាធិការកំណត់ផ្ទៃទីតាំងបឹងបូរ ក្នុងព្រះរាជាណាចក្រកម្ពុជា មានភារកិច្ចដូចតទៅ :

- ជាសេនាធិការទទួលបន្ទុកបច្ចេកទេស និងច្បាប់ឱ្យគណៈកម្មាធិការកំណត់ផ្ទៃទីតាំងបឹងបូរ ក្នុងព្រះរាជាណាចក្រកម្ពុជា
- ទទួលរៀបចំផែនការការងារ និងកិច្ចប្រជុំរបស់គណៈកម្មាធិការ
- សម្របសម្រួល និងទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន ដែលជាសមាជិក គណៈកម្មាធិការកំណត់ផ្ទៃទីតាំងបឹងបូរ ក្នុងព្រះរាជាណាចក្រកម្ពុជា

- បំពេញការងារផ្សេងៗទៀត តាមការណែនាំរបស់គណៈកម្មាធិការកំណត់ថ្លៃទីតាំងបឹងបូរ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៦ :** រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៧ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ៨ ០៧ ឆ្នាំ ២០០៧

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៧
- ឯកសារ-កាលប្បវត្តិ